# ការគ្រប់គ្រងជំងឺនៅសាលារៀន និងកន្លែងអប់រំកុមារតូច

កិច្ចការមួយដ៏សំខាន់បំផុតដែលយើងអាចធ្វើបាន ដើម្បីកាត់បន្ថយការរីករាលដាលនៃវីរុសកូរ៉ូណា (COVID-19) នៅក្នុងសហគមន៍របស់យើង គឺត្រូវនៅផ្ទះពេលណាយើងមិនស្រួលខ្លួន សូម្បីតែពេលណាដែលយើងមានរោគសញ្ញាស្រាលបំផុតក៏ដោយ។

## អ្វីដែលអ្នកចាំបាច់ត្រូវដឹង

### ប្រសិនបើកុមារមិនស្រួលខ្លួន សូម្បីតែមានរោគសញ្ញាស្រាលបំផុតក៏ដោយ ពួកគេត្រូវតែនៅផ្ទះ

ប្រសិនបើកុមារមានអាការៈមិនស្រួលខ្លួននៅពេលថ្ងៃ ពួកគេត្រូវបានយកចេញពីសាលារៀន និងកន្លែងអប់រំ និងថែទាំកុមារតូច (ECEC) ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។

### ប្រសិនបើកុមារមានរោគសញ្ញាណាមួយនៃវីរុសកូរ៉ូណា (COVID-19) ដូចដែលបានរៀបរាប់ខាងក្រោម ទោះជាស្រាលយ៉ាងណាក៏ដោយ ពួកគេគួរតែធ្វើតេស្ត ហើយពួកគេត្រូវតែនៅក្នុងផ្ទះ រហូតដល់ទទួលបានលទ្ធផលរបស់ពួកគេ៖

- គ្រុនក្តៅ
- ញាក់ ឬបែកញើស
- ក្អក
- ឈឺបំពង់ក
- ដង្ហើមខ្លី
- ហៀរសំបោរ
- បាត់បង់ការស្រង់ក្លិន ឬរសជាតិ។

នៅក្នុងកាលៈទេសៈខ្លះឈឺក្បាល ឈឺសាច់ដុំ តឹងច្រមុះ ដំណើរចង់ក្អួត ក្អួត និងចុះរាគក៏អាចត្រូវបានគេចាត់ទុកថាជារោគសញ្ញាដែរ។

សម្រាប់ដំបូន្មានបន្ថែម៖

- ហៅទូរស័ព្ទទាន់ហេតុការណ៍ 24-ម៉ោង ស្តីពីវីរុសកូរ៉ូណា (COVID-19) លេខ 1800 675 398
- ទូរស័ព្ទទៅវេជ្ជបណ្ឌិត
- ប្រើឧបករណ៍វាយតម្លៃដោយខ្លួនឯងតាមអនឡាញ របស់ក្រសួងសុខាភិបាល (Department of Health - DHS)។

បើកចូល៖ កន្លែងដែលត្រូវទៅធ្វើតេស្ត។

# កុមារត្រូវតែនៅផ្ទះរហូតដល់ពួកគេលែងឃើញមានរោគសញ្ញា ទោះបីជាការធ្វើតេស្តរកមើលវីរុសកូរ៉ូណា (COVID-19) ជាអវិជ្ជមានក៏ដោយ

ប្រសិនបើមនុស្សម្នាក់ត្រូវបានធ្វើតេស្តរកមើលវីរុសកូរ៉ូណា (COVID-19) ឬត្រូវបានកំណត់អត្តសញ្ញាណថាជាមនុស្សមានទំនាក់ទំនងជិតស្និទ្ធ ពួកគេត្រូវតែដាក់ខ្លួនឱ្យនៅដាច់ពីគេ/ដាក់ឱ្យនៅដាច់ដោយឡែកពីគេ រហូតដល់ពួកគេបានទទួលលិខិតបញ្ជាក់ស្តីពីការរួចផុតពីតម្រូវការដាក់ខ្លួនឱ្យនៅដាច់ពីគេ ពី DHS។

កុមារដែលមានរោគសញ្ញាមិនជាសះស្បើយដោយសារតែមានស្ថានភាពរោគ ដូចជារោគផ្តាសាយ តឹងច្រមុះ  ឬជំងឺហឺត ដែលរោគសញ្ញារបស់ពួកគេគឺជាលក្ខណៈធម្មតានៃស្ថានភាពរោគរបស់ពួកគេ អាចបន្តទៅ ECEC/សាលារៀន។ ពួកគេគួរតែបានធ្វើតេស្តរកមើលជំងឺ COVID-19 ប្រសិនបើពួកគេមានរោគសញ្ញាខុសគ្នា ឬអាក្រក់ជាងរោគសញ្ញាធម្មតារបស់ពួកគេ។ ពួកគេគួរតែពិចារណាដើម្បីទទួលសំបុត្រពេទ្យពីវេជ្ជបណ្ឌិតដើម្បីទៅ ECEC/សាលារៀន។ ប្រសិនបើពួកគេមានរោគសញ្ញាមិនជាសះស្បើយដែលអាចកើតមានជួនពេលគ្នានឹងរោគសញ្ញានៃជម្ងឺ COVID-19 ដូចជាក្អក ឬហៀរសំបោរ។

ក្មេងតូចៗ (ថ្នាក់មត្តេយ្យ រហូតដល់ថ្នាក់ទី 2) អាចមានរោគសញ្ញាក្រោយឆ្លងរោគមានរយៈពេលយូរវែងអន្លាយ ដូចជាហៀរសំបោរ ឬក្អក ហើយអាចវិលត្រឡប់ទៅសាលារៀន/ECEC វិញ បន្ទាប់ពីការធ្វើតេស្តអវិជ្ជមានសម្រាប់ជំងឺ COVID-19 ទោះបីជាពួកគេមិនមានរោគសញ្ញាទាំងស្រុងក៏ដោយ។ ពួកគេនឹងចាំបាច់ត្រូវការសំបុត្រពេទ្យពីវេជ្ជបណ្ឌិតរបស់ពួកគេ ដើម្បីបញ្ជាក់ថាពួកគេមានសុខភាពល្អ ឬបានជាសះស្បើយពីជំងឺធ្ងន់ធ្ងររបស់ពួកគេ។

សម្រាប់ព័ត៌មានស្តីពីរយៈពេលអប្បបរមាដែលសិស្ស និងកុមារចាំបាច់ត្រូវការនៅផ្ទះសម្រាប់ស្ថានភាពរោគផ្សេងទៀត សូមមើល តារាងការហាមមិនឱ្យទៅសាលារៀន DHS។

# កុមារមិនចាំបាច់ត្រូវការសំបុត្រពេទ្យទេ មុនពេលត្រឡប់ទៅសាលារៀន/ECEC វិញ

នៅពេលរោគសញ្ញាបានជះស្រឡះហើយ មិនមានតម្រូវការពីក្រសួងអប់រំ និងបណ្តុះបណ្តាល (Department of Education and Training) ឬ DHS សម្រាប់កុមារ/សិស្សឱ្យមានសំបុត្រពេទ្យ មុនពេលពួកគេត្រឡប់ទៅសាលារៀន / ECEC វិញទេ។

## សូមអរគុណចំពោះការគាំទ្ររបស់អ្នកក្នុងការធ្វើតាមជំហានទាំងនេះ យើងទាំងអស់គ្នាអាចរក្សាសុវត្ថិភាពជាមួយគ្នា។

ជំបូន្មាននេះត្រូវបានរៀបចំឡើងដោយក្រសួងអប់រំ និងបណ្តុះបណ្តាល (Department of Education and Training), ការថែទាំមានសុវត្ថិភាព វេដ្ឋវិចថូរៀ (Safer Care Victoria) និងក្រសួងសុខាភិបាល (Department of Health)